# សិទ្ធិមនុស្ស និងធុរកិច្ច
# គោលការណ៍ណែនាំ
# របស់អង្គការសហប្រជាជាតិស្តីពី
# ធុរកិច្ច និងសិទ្ធិមនុស្ស

ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ

ភ្នំពេញ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០១៤

# សង្ខេបបទបង្ហាញ

- ✓សេចក្តីផ្តើម សិទ្ធិមនុស្ស ធុរកិច្ច និង CSR ច្បាប់និងបទដ្ឋានអន្តរជាតិពាក់ព័ន្ធ
- ✓គោលការណ៍ណែនាំអ.បស.ពីសិទ្ធិមនុស្ស និងធុរកិច្ច
- ✓ភាពពាក់ព័ន្ធនៃធុរកិច្ចនិងសិទ្ធិមនុស្សចំពោះកម្ពុជា
- ✓បខ័ណ្ឌ ការពារ គោរព និងដោះស្រាយ (សសរស្តម្ភទាំង៣)
- ✓សារៈប្រយោជន៍នៃគោលការណ៍ណែនាំ

# <u>ផ្នែកទី១</u>-សេចក្តីផ្តើមអំពីសិទ្ធិមនុស្ស ធុរកិច្ច និងការទទួលខុសត្រូវខាងសង្គមរបស់សាជីវកម្ម (CSR) ច្បាប់ និងបទដ្ឋានអន្តរជាតិពាក់ព័ន្ធ

# សិទ្ធិមនុស្ស

- ✓មានសិទ្ធិទទួលបានសិទ្ធិជាមូលដ្ឋានទាំងអស់
- ✓សម្រាប់មនុស្សគ្រប់រូប
- ✓ក្នុងគោលបំណងធានាបាននូវសេចក្ដីថ្លៃថ្នូរ និង ភាពស្មើគ្នា
- ✓ជាសាកល ទាក់ទងគ្នា និងអាស្រ័យគ្នាទៅវិញទៅមក និងមិនអាចញែកឲ្យដាច់ពីគ្នា
- ✓ឆ្លុះបញ្ចាំងនៅក្នុងគោលការណ៍ និងបទដ្ឋាន

# សិទ្ធិមនុស្ស និងការទទួលខុសត្រូវ

- ✓ <u>សិទ្ធិមនុស្ស</u>មាន៖ <u>សិទ្ធិ</u> និង <u>ការទទួលខុសត្រូវ</u>

- ✓ រដ្ឋមានភារកិច្ច និងការទទួលខុសត្រូវ៖
  - ✓ គោរពសិទ្ធិមនុស្ស
  - ✓ ការពារសិទ្ធមនុស្ស
  - ✓ ធ្វើឲ្យទទួលបានសិទ្ធិមនុស្សពេញលេញ

- ✓ បុគ្គលគ្រប់រូបមានទាំងសិទ្ធិ និងការទទួលខុសត្រូវ
  - ✓ យើងមានសិទ្ធិទទួលបានសិទ្ធិមនុស្សទាំងអស់ ដូច្នេះ យើងត្រូវគោរពសិទ្ធិអ្នកដទៃ

# ធុរកិច្ច

- ✓សហគ្រាសពាណិជ្ជកម្មទាំងអស់(សាជីវកម្ម អាជីវកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាស គ្រឹះស្ថាន)ទាំងជា៖
  - ✓ទំរង់ឆ្លងដែន និងទំរង់ដទៃទៀត
  - ✓មិនគិតពីវិស័យ ឬប្រទេសដែលសហគ្រាសពាណិជ្ជកម្ម តាំងនៅ ឬ ធ្វើប្រតិបត្តការ
  - ✓ដោយមិនគិតពីទំហំ ទំរង់ ឬរចនាសម្ព័ន្ធ
  - ✓រាប់ទាំងសហគ្រាសជាលក្ខណៈគ្រួសារ។

# ការទទួលខុសត្រូវខាងសង្គមរបស់សាជីវកម្ម(CSR)-១

- ✓ CSR ចាប់ផ្តើមចុងទសវត្សរ៍១៩៦០ ដើម ១៩៧០
- ✓ ជាទូទៅមានសមាសធាតុ៖
  - ✓ តម្លៃស្នូល សីលធម៌ គោលនយោបាយ និងការអនុវត្តសកម្មភាពធុរកិច្ច របស់ធុរកិច្ច
  - ✓ ការចូលរួមចំណែកដោយស្ម័គ្រចិត្តរបស់ធុរកិច្ចចំពោះការអភិវឌ្ឍន៍របស់សហគមន៍
  - ✓ គ្រប់គ្រងបញ្ហាសង្គម និងបរិស្ថានក្នុងរង្វង់តម្លៃសង្វាក់ផលិតកម្មក្នុងក្រុមហ៊ុន និងដៃគូធុរកិច្ចរបស់ខ្លួន--តាំងពីពេលទទួលវត្ថុធាតុដើម ផលិត មានទាំងសុខមាលភាពបុគ្គលិក រហូតដល់លក់ ប្រើប្រាស់ និងបោះចោលផលិតផល

# ការទទួលខុសត្រូវខាងសង្គមរបស់សាជីវកម្ម(CSR)-២

កម្មវិធីទទួលខុសត្រូវខាងសង្គមរបស់សាជីវកម្ម(CSR)ដែលធុរកិច្ចអនុវត្ត៖

- ✓ជាវិធីដែលក្រុមហ៊ុន បញ្ចូលនូវកង្វល់ខាងសេដ្ឋកិច្ច សង្គម និងបរិស្ថានទៅក្នុងសកម្មភាពរបស់ខ្លួន។
- ✓ជានិច្ចកាលអនុវត្តដោយជ្រើសរើស លក្ខណៈបណ្ដោះអាសន្ន និងគ្រាន់តែជាទង្វើមនុស្សធម៌តែប៉ុណ្ណោះ។
- ✓ផ្អែកតែលើអ្វីដែលក្រុមហ៊ុនជ្រើសរើសដោះស្រាយដោយស្ម័គ្រចិត្ត។

# ច្បាប់និងបទដ្ឋានអន្តរជាតិពាក់ព័ន្ធនឹងធុរកិច្ច និងសិទ្ធិមនុស្ស

- ✓ ច្បាប់សិទ្ធិមនុស្សអន្តរជាតិនិយាយសំដៅកាតព្វកិច្ចរបស់រដ្ឋក្នុងការគោរព ការពារ និងធ្វើអោយទទួលបានសិទ្ធិមនុស្សពេញលេញ
- ✓ កាតព្វកិច្ចក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិមិននិយាយសំដៅចំពោះបុគ្គលឯកជន និងសាជីវកម្ម
- ✓ មានកង្វល់ជាច្រើនអំពីផលប៉ះពាល់អវិជ្ជមាននៃសាជីវកម្មពហុជាតិ ជាពិសេសកើតមានឡើងតាំងពីទសវត្សឆ្នាំ ១៩៧០
- ✓ មានកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់ដោយអង្គការសហប្រជាជាតិដើម្បីឆ្លើយតប/ដោះស្រាយកង្វល់ទាំងនេះ។

# ច្បាប់និងបទដ្ឋានអន្តរជាតិពាក់ព័ន្ធនឹងធុរកិច្ច និងសិទ្ធិមនុស្ស

| | |
|---|---|
| ចុងទសវត្សឆ្នាំ១៧០០ | លុបបំបាត់ទាសភាព និងពលកម្មកុមារ (លោកខាងលិច) |
| ឆ្នាំ១៩១៩ | ការបង្កើតឡើងអង្គការពលកម្មអន្តរជាតិ ILO |
| ឆ្នាំ១៩៤៨ | សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស |
| ឆ្នាំ១៩៦៦ | ការបើកអោយរដ្ឋជាសមាជិកអ.ប ចុះហត្ថលេខា ICCPR និង ICESR |
| ឆ្នាំ១៩៧៣ | អ.ប បង្កើតគណកម្មាធិកាស្តីពីសាជីវកម្មពហុជាតិ (រំលាយវិញក្នុងឆ្នាំ១៩៩៤) |
| ឆ្នាំ១៩៧៦ | ការចូលជាធរមាននូវ ICCPR និង ICESR<br>ការអនុម័តនូវ OECD Guidelines for Multinational Enterprises |
| ឆ្នាំ១៩៩៨ | អ.ប បង្កើត ក្រុមការងារស្តីពីសាជីវកម្មពហុជាតិ |
| ឆ្នាំ២០០៣ | ការផ្សព្វផ្សាយក្រុមស្តីពីការទទួលខុសត្រូវនៃសាជីវកម្មពហុជាតិ និងសហគ្រាសពាណិជ្ជកម្មដទៃទៀតទាក់ទងនឹងសិទ្ធិមនុស្ស (ក្រមត្រូវបានបដិសេធក្នុងឆ្នាំ២០០៤) |
| ឆ្នាំ២០០៥ | សាស្រ្តាចារ្យ ចន រូហ្គី ត្រូវបានតែងតាំងជាតំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការស.បស្តីពីបញ្ហាធុរកិច្ច និងសិទ្ធិមនុស្ស |
| ឆ្នាំ២០០៦ | ក្របខ័ណ្ឌ ការពារ គោរព និងដោះស្រាយ ត្រូវបានអនុម័តយល់ព្រមដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស |
| ឆ្នាំ២០១១ | គោលការណ៍នែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្សត្រូវបានអនុម័តជាឯកច្ឆ័ន្ទដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស OECD Guidelines ត្រូវបានធ្វើវិសោធនកម្ម ដោយដាក់បញ្ចូលនូវជំពូកអំពីសិទ្ធិមនុស្ស ។ |

# ដំណើរឆ្ពោះទៅមុខលើសពីអ្វីដែលគ្រាន់តែជា‘CSR’






ក្នុងខែមិថុនា ឆ្នាំ២០១១ អង្គការសហប្រជាជាតិ-ក្រុមប្រឹក្សាសិទ្ធិមនុស្ស អនុម័តជាឯកឆ័ន្ទនូវសំណុំគោលការណ៍ណែនាំ ដើម្បីធានាថាក្រុមហ៊ុនមិនរំលោភសិទ្ធិមនុស្ស នៅក្នុងប្រតិបត្តិការសកម្មភាពធុរកិច្ចរបស់ខ្លួន និងធានាថាពួកគេផ្តល់នូវដំណោះស្រាយនៅពេលមានករណីរំលោភបំពានកើតឡើង។

# សិទ្ធិមនុស្ស និងធុរកិច្ច?

- ✓ជាទូទៅធុរកិច្ចរួមចំណែកវិជ្ជមានចំពោះការអភិវឌ្ឍន៍
- ✓ប៉ុន្តែក៏មានការប៉ះពាល់អវិជ្ជមានផងដែរ
- ✓កន្លងមកធុរកិច្ចអនុវត្តតែកម្មវិធីទទួលខុសត្រូវខាងសង្គមរបស់សាជីវកម្ម
- ✓មានការចោទប្រកាន់អំពីការរំលោភបំពានប្រព្រឹត្តដោយធុរកិច្ច
- ✓សង្គមស៊ីវិលផ្តោតលើបញ្ហានេះកាន់តែខ្លាំង

# សិទ្ធិមនុស្ស និងធុរកិច្ច

- ✓ ការគោរពសិទ្ធិមនុស្ស៖
  - ✓ពុំមែនជាការអនុវត្តដោយស្ម័គ្រចិត្ត
  - ✓ទាមទារការប្តេជ្ញាចិត្តពីធុរកិច្ច
  - ✓ដើម្បីបំពេញការទទួលខុសត្រូវរបស់ខ្លួនក្នុងការគោរពសិទ្ធិមនុស្ស៖ ធុរកិច្ចត្រូវអនុវត្តគោលនយោបាយដើម្បីទប់ស្កាត់ និងដោះស្រាយផលប៉ះពាល់ជាអវិជ្ជមាននៃសកម្មភាពខ្លួន
- ✓ ខុសគ្នាពី(CSR) ប៉ុន្តែបំពេញគ្នាទៅវិញទៅមកលើការទទួលខុសត្រូវខាងសង្គមរបស់សហគ្រាស (CSR)។

# សិទ្ធិមនុស្ស និងធុរកិច្ច

- ✓ អនុវត្តច្បាប់
- ✓ គោរពសិទ្ធិមនុស្សដែលមានការទទួលស្គាល់ជាអន្តរជាតិទាំងអស់
- ✓ អនុវត្តដំណើរការនៃការប្រព្រឹត្តដោយត្រឹមត្រូវលើសិទ្ធិមនុស្ស
- ✓ ពិគ្រោះយោបល់ជាមួយអ្នកដែលអាចនឹងរងផលប៉ះពាល់
- ✓ ធ្វើអោយមានការអនុវត្តតាមគោលការណ៍នៃនាំក្នុងសង្វាក់ផលិតកម្ម
- ✓ បង្កើតឡើងនូវយន្តការប្រកបដោយប្រសិទ្ធិភាពសម្រាប់ដោះស្រាយបណ្តឹង/ទំនាស់
- ✓ មានតម្លាភាពចំពោះគោលនយោបាយ សកម្មភាព និងផលប៉ះពាល់សិទ្ធិមនុស្ស និង
- ✓ ធ្វើសេចក្តីរាយការណ៍ជាសាធារណៈអំពីបញ្ហាសិទ្ធិមនុស្ស

# សិទ្ធិមនុស្ស និងធុរកិច្ច?

អ្វីជាផលវិបាកនៃការ.........

✓មិនគោរពច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយ

✓មិនពិគ្រោះយោបល់ជាមួយអ្នកដែលរងការប៉ះពាល់ដោយសកម្មភាពធុរកិច្ច?

- ✓ សហគមន៍ និងតួអង្គផ្សេងៗដែលធ្វើប្រតិបត្តិការក្នុងវិស័យនេះ
- ✓ អាជ្ញាធរថ្នាក់ក្រោមក៏ដូចជាថ្នាក់ជាតិ

✓មិនមានផែនការទុកជាមុន អំពីការវាយតំលៃផលប៉ះពាល់?

✓មិនគោរពបរិស្ថាន និងប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព

✓មិនចែករំលែកព័ត៌មាន/ប្រព្រឹត្តដោយខ្វះតម្លាភាព?

✓មិនគោរពសិទ្ធិរបស់កម្មករ/និយោជិត និងបទដ្ឋានខាងការងារ?

# ផ្នែកទី២-គោលការណ៍ណែនាំអង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស និងធុរកិច្ច

# គោលការណ៍ណែនាំអ.បស្តីពីសិទ្ធិមនុស្ស និងធុរកិច្ច

<u>ការនាំមកនូវគោលការណ៍ណែនាំ</u>

*សាកលភាវូបនីយកម្មៈ*

✓ភាពខ្វះខាតផ្នែកអភិបាលកិច្ចល្អ

✓ការឆ្លើយតបរបស់ធុរកិច្ចជាលក្ខណៈស្ម័គ្រចិត្ត (CSR)

✓ខ្វះគំនិតរួមថា អ្វីទៅជាការទទួលខុសត្រូវរបស់ធុរកិច្ចចំពោះសិទ្ធិមនុស្ស?

# គោលការណ៍ណែនាំអ.បស្តីពីសិទ្ធិមនុស្ស និងធុរកិច្ច

## ការនាំមកនូវគោលការណ៍ណែនាំ

*អ.ស.ប ធុរកិច្ច និង សិទ្ធិមនុស្ស៖*

- ✓ឆ្នាំ២០០២ មាន យូអិនគ្លូបលកំផែក-មានគំនិតរួមថា ធុរកិច្ចគួរតែគាំទ្រ និងគោរពសិទ្ធិមនុស្ស និងជៀសវាងចូលរួមសមគំនិតក្នុងការរំលោភសិទ្ធិមនុស្ស
- ✓ឆ្នាំ២០០៥ លោកអគ្គលេខាអ.ស.ប តែងតាំងតំណាងពិសេសស្តីពីសិទ្ធិមនុស្ស និងធុរកិច្ច។

# តំណាងពិសេស

- ✓ លោកសាស្ត្រាចារ្យ **ចន រូហ្គី**
- ✓ ក្រុមប្រឹក្សាសិទ្ធិមនុស្សផ្តល់អាណត្តិឲ្យ
  - ☑ កំណត់ និងស្រាយបំភ្លឺអំពីស្តង់ដានៃការទទួលខុសត្រូវរបស់សាជីវកម្មចំពោះសិទ្ធិមនុស្ស
  - ☑ ស្រាយបំភ្លឺអំពីតួនាទីរបស់រដ្ឋ
- ✓ **ផ្តែកលើភស្តុតាង៖** ការស្រាវជ្រាវដ៏ទូលំទូលាយ ដោយមានការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ រួមបញ្ចូលទាំងអ្នកធុរកិច្ចផងដែរ
- ✓ ជំហានទី១ (ឆ្នាំ២០០៥-២០០៨)៖ ក្របខណ្ឌ"**ការពារ គោរព និង ដោះស្រាយ**" ("ក្របខណ្ឌរូហ្គី")
- ✓ ជំហានទី២ (ឆ្នាំ២០០៨-២០១១)៖ **គោលការណ៍ណែនាំ អ.ស.ប ស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស**

# គោលការណ៍ណែនាំអ.ស.បស្តីពីសិទ្ធិមនុស្ស និងធុរកិច្ច

- ✓ អនុម័តជាឯកច្ឆ័នដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស នៅក្នុងខែមិថុនា ឆ្នាំ២០១១ - មូលដ្ឋានគ្រឹះនយោបាយរឹងមាំ-ឯកសារបទដ្ឋានយោងជាសាកលលើកទីមួយ អនុម័តដោយសមាជិកអ.ស.ប ដែលដោះស្រាយផលប៉ះពាល់របស់ធុរកិច្ចលើសិទ្ធិមនុស្ស
- ✓ រដ្ឋជាសមាជិកអ.ស.បទាំងអស់
- ✓ ក្រុមហ៊ុនទាំងអស់ គ្រប់ខ្នាត គ្រប់វិស័យ
- ✓ សិទ្ធិមនុស្សដែលត្រូវទទួលស្គាល់ជាសាកលទាំងអស់
- ✓ មាន៣១ គោលការណ៍ សម្រាប់ណែនាំទាំង រដ្ឋ និងធុរកិច្ច៖ គ្រប់គ្រង និងដោះស្រាយ ហានិភ័យសិទ្ធិមនុស្ស
- ✓ សម្រាប់អនុវត្ត **ក្របខណ្ឌ“ការពារ គោរព និងដោះស្រាយ”**

# គោលការណ៍ណែនាំអ.បស្តីពីសិទ្ធិមនុស្ស និងធុរកិច្ច

- មិនមែនជាបទដ្ឋានថ្មី--ពុំមានកាតព្វកិច្ចតាមច្បាប់ថ្មីណានោះទេ ប៉ុន្តែពន្យល់អំពីរបៀបដែលរដ្ឋ ធុរកិច្ច និងសហគមន៍អន្តរជាតិ អាចអនុវត្តបាននូវក្របខ័ណ្ឌ ការពារ គោរព និងដំណោះស្រាយ ។
- បង្កើតឡើងនូវក្រុមការងារដើម្បីលើកកម្ពស់ និងត្រួតពិនិត្យមើលលើការអនុវត្តគោលការណ៍ណែនាំនេះ
- វេទិកាប្រចាំឆ្នាំប្រព្រឹត្តិទៅនៅទីក្រុងហ្សឺណែវជាមួយអ្នកពាក់ព័ន្ធនានាដើម្បីយល់ដឹងពីភាពរីកចម្រើននៃគោលការណ៍ណែនាំ។

# ផ្នែកទី៣-ភាពពាក់ព័ន្ធចំពោះប្រទេសកម្ពុជា

# ទំនាក់ទំនងនៃធុរកិច្ចនិងសិទ្ធិមនុស្សចំពោះកម្ពុជា

✓ តើមានប្រភេទធុរកិច្ចអ្វីខ្លះដែលកំពុងមានប្រតិបត្តិការនៅប្រទេសកម្ពុជា?

✓ តើធុរកិច្ចនិងសិទ្ធិមនុស្សពាក់ព័ន្ធយ៉ាងដូចម្តេចនៅក្នុងបរិបទប្រទេសកម្ពុជា?

✓ តើអ្វីជាក្របខណ្ឌច្បាប់គ្រប់គ្រងសកម្មភាពធុរកិច្ចនាពេលបច្ចុប្បន្ន?

# ទាពពាក់ព័ន្ធចំពោះប្រទេសកម្ពុជា

វិស័យធុរកិច្ច ដែលពាក់ព័ន្ធនឹងបរិបទកម្ពុជា៖

- ✓ **កសិឧស្សាហកម្ម**(ដីសម្បទានសេដ្ឋកិច្ច)ដូចជា អំពៅ កៅស៊ូ ដំឡូងមី អាកាស្យា
- ✓ **សហគ្រាស**នៅតាមទីប្រជុំជន និងទីជនបទ៖ រោងចក្រ
- ✓ **ឧស្សាហកម្មនិស្សារណកម្ម៖** ការយករ៉ែ ប្រេង និងឧស្ម័ន
- ✓ **ទេសចរណ៍ និងបដិសណ្ឋារកិច្ច៖** សណ្ឋាគារ និងភោជនីយដ្ឋាន
- ✓ **ហេដ្ឋារចនាសម្ព័ន្ធ និងគ្រោងការណ៍អភិវឌ្ឍន៍ផ្សេងៗ៖**ស្ពាបនាផ្លូវដែក ផ្លូវថ្នល់
- ✓ **សេវាជ្រើសរើសបុគ្គលិក**
- ✓ **គម្រោងថាមពល៖** ទំនប់វារីអគ្គីសនី និងរោងចក្រអគ្គីសនីដុតធ្យូងថ្ម
- ✓ **សហគ្រាសខ្នាតតូច និងមធ្យមផ្សេងៗទៀត (+អាជីវកម្មជាលក្ខណៈគ្រួសារ)**

# ភាពពាក់ព័ន្ធចំពោះប្រទេសកម្ពុជា

អនុវត្តដោយផ្ទាល់ចំពោះកម្ពុជា តាមរយៈការប្តេជ្ញាតាមច្បាប់អន្តរជាតិ និងច្បាប់ជាតិរបស់ខ្លួន៖

- ✓ ប្រទេសកម្ពុជាបានចុះហត្ថលេខានិងផ្តល់សច្ចាប័នលើលើសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ព្រមទាំងអនុសញ្ញាILOសំខាន់ៗទាំង៨
- ✓ រដ្ឋធម្មនុញ្ញមាត្រា៣១ ចែងអំពីកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់កម្ពុជា
- ✓ គោលការណ៍ណែនាំនេះបានឈរលើកាតព្វកិច្ចស្រាប់របស់រដ្ឋក្នុងការការពារ គោរព និងធ្វើអោយទទួលបានពេញលេញនូវសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន។
- ✓ បន្ថែមពីលើចំនុចខាងលើ (ក្នុងស្រុកមានដូចជា ច្បាប់ការងារ និងបញ្ញត្តិមានពាក់ព័ន្ធដទៃទៀត)

# ទំនាក់ទំនងនៃធុរកិច្ចនិងសិទ្ធិមនុស្សចំពោះកម្ពុជា

វិស័យកាត់ដេរមានក្របខ័ណ្ឌច្បាប់ជាក់លាក់មួយចំនួន៖

- ✓ ច្បាប់ការងារ និងបទប្បញ្ញត្តិពាក់ព័ន្ធ.....
- ✓ អនុសញ្ញាILOសំខាន់ទាំង៨
- ✓ សេចក្តីសំរេចរបស់រដ្ឋាភិបាល.....

# ផ្នែកទី៨-ក្របខ័ណ្ឌគោរព ការពារ និង ដំណោះស្រាយ

# ក្របខ័ណ្ឌ ការពារ គោរព និងដោះស្រាយ
## (សសរស្តម្ភទាំង៣)

| | | |
|---|---|---|
| **រដ្ឋ** មានភារកិច្ច **ការពារ** សិទ្ធិមនុស្ស | **សាជីវកម្ម** មានការ ទទួលខុសត្រូវ **គោរព** សិទ្ធិមនុស្ស | ការទទួលបាន **ដំណោះស្រាយ** ប្រកបដោយ ប្រសិទ្ធិភាព |

# រដ្ឋមានភារកិច្ចការពារសិទ្ធិមនុស្ស- (សសរស្តម្ភទី១) តាមរយៈច្បាប់ និងគោលនយោបាយ

មានច្បាប់ និងគោលនយោបាយគ្រប់គ្រាន់

អនុវត្ត

ការណែនាំ

ការប្រាស្រ័យទាក់ទងធុរកិច្ច

តើលើទឹកចិត្ត ឬក៏បង្អាក់ដល់ការគោរពសិទ្ធិមនុស្សរបស់ធុរកិច្ច?

✓តើអ្នកពាក់ព័ន្ធចូលរួមយ៉ាងដូចម្តេច?

# សាជីវកម្មមានការទទួលខុសត្រូវគោរពសិទ្ធិមនុស្ស (សរសរស្តម្ភទី២)

**គោលការណ៍ លេខ ១១**

-គោរព = មិនធ្វើឲ្យប៉ះពាល់ និងដោះស្រាយការប៉ះពាល់
-គោរពសិទ្ធិមនុស្សដែលទទួលស្គាល់ទាំងអស់
-ចំពោះគ្រប់ធុរកិច្ចទាំងអស់

- ✓ អនុវត្តគោលនយោបាយសិទ្ធិមនុស្ស គោលការណ៍ ១៦
- ✓ ប្រព្រឹត្តដោយត្រឹមត្រូវលើសិទ្ធិមនុស្ស គោលការណ៍១៧-២១ រួមទាំងដោះស្រាយផលប៉ះពាល់-ប្រើប្រាស់ឥទ្ធិពលខ្លួន (គោលការណ៍១៩)
- ✓ ជៀសវាងការបង្ក/រួមចំណែក+បង្ការ/កាត់បន្ថយផលប៉ះពាល់
- ✓ បង្កើតឡើងនូវយន្តការដោះស្រាយ ឬដំណើរការដទៃទៀតដើម្បីកែតម្រូវផលប៉ះពាល់ដែលបណ្តាលមកពីប្រតិបត្តិការធុរកិច្ច (គោលការណ៍ ២២ និង ២៩-៣១)

# ការពិនិត្យដោយត្រឹមត្រូវលើសិទ្ធិមនុស្ស (យល់ដឹង និងបង្ហាញ)

ការពិនិ្យដោយត្រឹមត្រូវលើសិទ្ធិមនុស្ស

- ✓ កំណត់ បង្ការ កាត់បន្ថយ និងមាន គណនេយ្យភាពចំពោះការដោះស្រាយ ផលប៉ះពាល់ (មានកត្តារួមផ្សំ៤)៖
  - ✓ **វាតំលៃអំពី**ផលប៉ះពាល់
  - ✓ **បូកបញ្ចូល** និងចាត់វិធានការលើការ រកឃើញអំពីផលប៉ះពាល់
  - ✓ **តាមដាន** ដោយមានការឆ្លើយតប
  - ✓ **ប្រាស្រ័យទាក់ទង** ដើម្បីដោះស្រាយ ផលប៉ះពាល់

*ចំនុចចាប់ផ្តើម៖ ការប្តេជ្ញាខាងគោលនយោបាយ*

*ការពិនិត្យដោយត្រឹមត្រូវ៖ ប្រើប្រាស់គ្រប់ការប្រុងប្រយ័ត្នចាំបាច់ និងសមហេតុផលទាំងអស់ ដើម្បីបង្ការព្យសនកម្ម*

- ✓ ការពិនិត្យដោយត្រឹមត្រូវគួរគ្របដណ្តប់លើផលប៉ះពាល់ ដែលបណ្តាលមកពី ឬ រួមចំណែកតាមរយៈសកម្មភាព ឬទំនាក់ទំនងនានារបស់ធុរកិច្ច
- ✓ ខុសគ្នាតាមខ្នាត ហានិភ័យ និងបរិបទ
- ✓ អនុវត្តជាបន្ត

# ការទទួលបានដំណោះស្រាយ (១)
# (សសរស្តម្ភទី៣)

1. យន្តការរបស់រដ្ឋ (តាមប្រព័ន្ធតុលាការ និង/ឬក្រៅពីប្រព័ន្ធតុលាការ)

2. យន្តការក្រៅក្របខ័ណ្ឌរដ្ឋ
   - ✓ កម្រិតប្រតិបត្តិការ
   - ✓ គំរិតអ្នកពាក់ព័ន្ធពហុភាគី/កម្រិតថ្នាក់ឧស្សាហកម្ម
   - ✓ ស្ថាប័នអភិវឌ្ឍន៍ថ្នាក់តំបន់
   - ✓ ស្ថាប័នសិទ្ធិមនុស្សថ្នាក់តំបន់ និងអន្តរជាតិ
   - ✓ ថ្នាក់អន្តរជាតិ

# ការទទួលបានដំណោះស្រាយ (២)
# (សសរស្តម្ភទី៣)

ក្រៅពីមានភារកិច្ចការពារ រដ្ឋត្រូវតែចាត់វិធានការនានា ដើម្បីធ្វើឲ្យទទួលបានដំណោះស្រាយមានប្រសិទ្ធិភាព ចំពោះការរំលោភសិទ្ធិមនុស្សដោយធុរកិច្ច៖

- ✓ តាមរយៈប្រព័ន្ធតុលាការ និង/ឬ
- ✓ តាមរយៈប្រព័ន្ធនានាក្រៅពីតុលាការ

# យន្តការរបស់រដ្ឋ៖ តាមរយៈប្រព័ន្ធតុលាការ

- ✓ ចាត់វិធានការដើម្បីធានាដល់ប្រសិទ្ធិភាពនៃយន្តការតុលាការក្នុងស្រុកចំពោះករណីរំលោភសិទ្ធិមនុស្សរបស់ធុរកិច្ច
- ✓ បញ្ចូលមធ្យោបាយដើម្បីកាត់បន្ថយរបាំងនានា (ឧបសគ្គ)

| របាំងនាំឲ្យមិនមានយុត្តិធម៌ |
|---|
| ទទួលឥទ្ធិពលពីធុរកិច្ច |
| សវនាការមិនគោរពតាមនិតិវិធីត្រឹមត្រូវ |
| ការផាត់ចេញក្រុមងាយរងគ្រោះពីការទទួលបានការការពារស្មើគ្នា |

| របាំងខាងនីតិវិធី និងការអនុវត្តន៍ជាក់ស្តែង |
|---|
| ថ្លៃចំណាយ |
| តំណាងផ្លូវច្បាប់ |
| ខ្វះជម្រើសសម្រាប់ធ្វើបណ្តឹងទាមទារជាសមូហភាព |
| កង្វះធនធាននៃស្ថាប័នអយ្យការ |

# យន្តការរបស់រដ្ឋ៖ ក្រៅប្រព័ន្ធតុលាការ

✓ ជាលក្ខណៈរដ្ឋបាល ឬលក្ខណៈសមស្របដទៃទៀត

✓ យន្តការមានប្រសិទ្ធិភាពដែលបំពេញឲ្យយន្តការតុលាការ

យន្តការទាំងនេះអាចមានទម្រង់ផ្សេងៗ៖

✓ជាលក្ខណៈការផ្សះផ្សា

✓ជាលក្ខណៈវិនិច្ឆ័យ

✓ផ្អែកលើភាពសមស្របនៃវប្បធម៌ ឬដំណើរការដែលផ្តោតលើសិទ្ធិ

ឧទាហរណ៍៖

✓ ស្ថាប័នសិទ្ធិមនុស្សជាតិឯករាជ្យ

✓ ប្រព័ន្ធដោះស្រាយទំនាស់ការងារ-ក្រុមប្រឹក្សាអជ្ញាកណ្តាល

✓ គណកម្មការដោះស្រាយបញ្ហាជាក់លាក់ផ្សេងទៀតដែលសមស្រប

# យន្តការដោះស្រាយក្រៅក្របខ័ណ្ឌរដ្ឋ

ដើម្បីបំពេញយន្តការដោះស្រាយរបស់រដ្ឋ៖ មាន យន្តការក្រៅក្របខ័ណ្ឌរដ្ឋ ដែលក្រុមហ៊ុនមួយ រួមជាមួយអ្នកពាក់ព័ន្ធ ឧ.សមាគមឧស្សាហកម្ម ឬក្រុមអ្នកពាក់ព័ន្ធដទៃទៀត បង្កើតឡើង។

✓ការទៅប្រើប្រាស់ និងការទទួលបាន ដំណោះស្រាយអាចមានល្បឿនលឿន និងកាត់បន្ថយចំណាយបានច្រើន

✓អាចទៅប្រើប្រាស់ជាលក្ខណៈឆ្លងដែន

-**កម្រិតប្រតិបត្តិការ៖** (ក្រុមហ៊ុនបង្កើតឡើងដើម្បីដោះស្រាយផលប៉ះពាល់)

-**កម្រិតអ្នកពាក់ព័ន្ធពហុភាគី/កំរិតថ្នាក់ឧស្សាហកម្ម** .........................

-**ថ្នាក់តំបន់** .........................

-**ស្ថាប័នសិទ្ធិមនុស្សថ្នាក់តំបន់ និងអន្តរជាតិ៖** គណៈកម្មការសិទ្ធិមនុស្សក្នុងតំបន់ ឧ. តុលាការសិទ្ធិមនុស្សអាស៊ាន (មិនទាន់បង្កើតនៅឡើយ) តុលាការសិទ្ធិមនុស្សអឺរ៉ុប ។ល។

-**ថ្នាក់អន្តរជាតិ**.........................

# យន្តការដោះស្រាយថ្នាក់ប្រតិបត្តិការ

✓ ដើម្បីដោះស្រាយវិវាទឲ្យបានលឿន និងផ្តល់ការដោះស្រាយដោយផ្ទាល់ ក្រុមហ៊ុននានាគួរបង្កើត ឬចូលរួមក្នុងយន្តការដោះស្រាយ**ថ្នាក់ប្រតិបត្តិការ** ដ៏មានប្រសិទ្ធិភាពនានា

មុខងារសំខាន់ពីរ៖

1. គាំទ្រការកំណត់ផលប៉ះពាល់ធ្ងន់ធ្ងរជា**ផ្នែកមួយនៃការពិនិត្យដោយត្រឹមត្រូវជាបន្ត**
2. ផ្តល់លទ្ធភាពដល់ការឆ្លើយតបឆាប់រហ័ស និងការដោះស្រាយដោយផ្ទាល់ –ជួយ**បង្ការការប៉ះពាល់កុំឲ្យរីកធំ** និងវិវាទកុំឲ្យកើនឡើង

# លក្ខណៈវិនិច្ឆ័យលើប្រសិទ្ធិភាពនៃយន្តការក្រៅព័ន្ធតុលាការ

តើស្របច្បាប់ឬទេ?

តើអាចទៅប្រើប្រាស់បានឬទេ?

តើអាចព្យាករណ៍ទុកឬទេ?

តើយុត្តិធម៌ឬទេ?

តើមានតម្លាភាពឬទេ?

តើមានសមិតភាពនឹង (គាំទ្រ) សិទ្ធិនានាឬទេ?

តើមានលក្ខណៈជាការសន្ទនាគ្នា និងដោយការចូលរួមឬទេ?

ការទទួលបានដំណោះស្រាយ៖ ជាផ្នែកសំខាន់នៃការទទួលខុសត្រូវរបស់សាជីវកម្ម និង ការត្រួតពិនិត្យត្រឹមត្រូវលើសិទ្ធិមនុស្ស (និងការគ្រប់គ្រងហានិភ័យ)

# <u>ផ្នែកទី៨</u>-សារៈប្រយោជន៍នៃគោលការណ៍ណែនាំ

# សារៈប្រយោជន៍នៃគោលការណ៍ណែនាំចំពោះរដ្ឋាភិបាល

✓**ធានាការពារបង្កានិងទប់ស្កាត់ការរំលោភបំពាន៖** ណែនាំអំពីជំហាននានាសម្រាប់ទប់ស្កាត់ការរំលោភបំពានពាក់ព័ន្ធនឹងធុរកិច្ច

✓**ភាពស៊ីសង្វាក់ខាងគោលនយោបាយ**

✓**ការកាត់បន្ថយហានិភ័យ៖** ណែនាំអំពីវិធានការច្បាស់លាស់នានា ដែលជួយកាត់បន្ថយហានិភ័យសិទ្ធិមនុស្ស ដែលធ្វើឲ្យរដ្ឋប្រឈមនឹងហានិភ័យនៃការខូចកិត្តិយសតិចតួចបំផុត

✓**ការទទួលបានព័ត៌មាន៖**តម្លាភាពលើកស្ទួយដល់ការសន្ទនានិងការចូលរួម

✓**ការទទួលបានដំណោះស្រាយ៖**ណែនាំអំពីការបំពេញកាតព្វកិច្ចផ្នែកគតិយុត្តិ និងធ្វើឲ្យប្រសើរឡើងដល់ប្រព័ន្ធដោះស្រាយការប៉ះពាល់/ទំនាស់

# សារៈប្រយោជន៍នៃគោលការណ៍ណែនាំចំពោះធុរកិច្ច

✓**បទដ្ឋានសម្រាប់ការតាមដានមើល**

✓**អត្ថប្រយោជន៍ខាងពាណិជ្ជកម្ម៖** អាចរួមចំណែកដល់៖

✓ការបង្កើនកិត្តិយស

✓កាន់តែងាយស្រួលក្នុងការទទួលបានទីផ្សារ អតិថិជន និងវិនិយោគិន

✓បង្កើនការពេញចិត្តរបស់កម្មករ--ង្កើនផលិតផលបាន និងបង្កើតស្ថេរភាពនៅក្នុងសង្វាក់ផលិតកម្ម

✓**កាត់បន្ថយហានិភ័យ៖** ការមិនអើពើនឹងសិទ្ធិមនុស្ស ប្រថុយនឹងហានិភ័យខ្ពស់ រួមមានហានិភ័យផ្លូវច្បាប់ ហិរញ្ញវត្ថុ កិត្តិយស និងការធ្វើប្រតិបត្តិការ។ល។

✓**ការទទួលបានព័ត៌មាន៖**តម្លាភាព និងព័ត៌មានគ្រប់គ្រាន់អាចសម្រួលដល់ការសន្ទនា និងកាត់បន្ថយវិវាទ

# សារៈប្រយោជន៍នៃគោលការណ៍ណែនាំចំពោះ ម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍

✓ក្របខណ្ឌសម្រាប់ការពិនិត្យពិច័យមើលលើដៃគូសាធារណៈនិងឯកជននានា

✓បំភ្លឺអំពីការទទួលខុសត្រូវនានា ចំពោះមុខនៃការគាំទ្ររបស់ខ្លួន ដោយមិនធ្វើឲ្យអន្តរាយដល់ភារកិច្ចរបស់រដ្ឋក្នុងការការពារ និងទំនួលខុសត្រូវរបស់សាជីវកម្មក្នុងការគោរពសិទ្ធិមនុស្ស។

# សារៈប្រយោជន៍សម្រាប់សង្គមស៊ីវិល (១)

ការពិនិត្យមើលជាទូទៅលើសិទ្ធិមនុស្ស៖

- ✓គោលនយោបាយសិទ្ធិមនុស្ស (គោលការណ៍១៦)
- ✓ការពិនិត្យមើលដោយត្រឹមត្រូវលើសិទ្ធិមនុស្ស (គោលការណ៍១៧ និង ២១)
- ✓ដំណើរការនៃការដោះស្រាយកែតម្រូវ (គ.ការណ៍២៥ ដល់ ៣១)
- ✓ការអនុវត្តតាមច្បាប់ និងបទដ្ឋាននានា (គ.ការណ៍២៣)

# សារៈប្រយោជន៍សម្រាប់សង្គមស៊ីវិល (២)

ការពិនិត្យមើលការដោះស្រាយ/ឆ្លើយតបចំពោះផលប៉ះពាល់សិទ្ធិមនុស្ស៖

១.កំណត់អំពីស្ថានភាពនៃការទទួលខុសត្រូវរបស់ធុរកិច្ច

✓ក្រុមហ៊ុនជាអ្នកបង្កនូវការរំលោភសិទ្ធិមនុស្ស

✓ក្រុមហ៊ុនចូលរួមចំណែកដល់ការរំលោភសិទ្ធិមនុស្ស

✓ក្រុមហ៊ុន មិនបង្ក និងមិនរួមចំណែក ប៉ុន្តែផលប៉ះពាល់មានទំនាក់ទំនងនឹងសកម្មភាពធុរកិច្ច

# សារៈប្រយោជន៍សម្រាប់សង្គមស៊ីវិល (៣)

<u>ការពិនិត្យមើលការដោះស្រាយ/ឆ្លើយតបចំពោះផលប៉ះពាល់សិទ្ធិមនុស្ស៖</u>

២. វាយតម្លៃពីការឆ្លើយតបចំពោះផលប៉ះពាល់សិទ្ធិមនុស្សរបស់សាជីវកម្ម

- ✓ការវាយតម្លៃ
- ✓ការពិគ្រោះយោបល់
- ✓ការដាក់បញ្ចូលលទ្ធផល
- ✓ផែនការសកម្មភាព
- ✓តាមដានប្រសិទ្ធិភាពនៃការឆ្លើយតប
- ✓ដោះស្រាយកែតម្រូវ
- ✓ប្រាស្រ័យឆ្លើយឆ្លង

# សារៈប្រយោជន៍សម្រាប់សង្គមស៊ីវិល (៨)

ការពិនិត្យមើលការដោះស្រាយ/ឆ្លើយតបចំពោះផលប៉ះពាល់សិទ្ធិមនុស្ស៖

៣. យុទ្ធសាស្ត្រជាបន្ត

✓ប្រាស្រ័យទាក់ទងជាមួយក្រុមហ៊ុន

✓បញ្ជូនករណីទៅតុលាការ រដ្ឋាភិបាល និងយន្តការដទៃទៀត

✓ផ្សព្វផ្សាយជាសាធារណៈអំពីករណីនៃការមិនគោរពសិទ្ធិមនុស្ស

✓ផ្តល់ព័ត៌មានអំពីការប៉ះពាល់សិទ្ធិមនុស្សធ្ងន់ធ្ងរដល់ដៃគូរនានានៃធុរកិច្ចដែលរំលោភសិទ្ធិមនុស្ស

# ប្រភពធនធានព័ត៌មាន និងការអានបន្ថែម

| | |
|---|---|
| UN Guiding Principles on Business and Human Rights | http://www.ohchr.org/Documents/Publications/GuidingPrinciplesBusinessHR_EN.pdf |
| The Institute for Human Rights and Business | www.ihrb.org |
| OECD Guidelines for Multinational Enterprises | www.oecd.org/dataoecd/43/29/48004323.pdf |
| IFC Sustainability Framework | www.oecd.org/dataoecd/43/29/48004323.pdf |
| The Equator Principles | www.equator-principles.com |
| The Business and Human Rights Resource Centre | www.business-humanrights.org |
| The Global Compact | www.unglobalcompact.org |
| The Global Reporting Initiative | www.globalreporting.org |
| A4ID Discussion Paper on Law Firms and the Guiding Principles | http://www.a4id.org/resource/report/guidingprinciples |

# អរគុណ!